**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ : ...០៥០...ក.ល.

# សេចក្តីជូនដំណឹងស្តីពី

## ការអញ្ជើញចូលរួមដេញថ្លៃការងារសាងសង់ អគារស្នាក់នៅជនវិបល្លាសស្មារតី កំរិត មធ្យម និងធ្ងន់ អគារផ្ទះបាយ និងឃ្លាំងស្តុកសម្ភារៈ ដំបូលផ្លូវដើរ បន្ទប់ទឹកជនវិបល្លាសស្មារតី និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ជូនមជ្ឈមណ្ឌលទទួលថែទាំ និង ព្យាបាលជនវិបល្លាសស្មារតី (ជនវិកលចរិក) ខេត្តកណ្តាល

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការ ធ្វើការងារសាងសង់ អគារស្នាក់នៅជនវិបល្លាសស្មារតី កំរិត មធ្យម និងធ្ងន់ អគារផ្ទះបាយ និងឃ្លាំងស្តុកសម្ភារៈ ដំបូលផ្លូវដើរ បន្ទប់ទឹកជនវិបល្លាសស្មារតី និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ជូនមជ្ឈមណ្ឌលទទួលថែទាំ និង ព្យាបាលជនវិបល្លាសស្មារតី (ជនវិកលចរិក) ខេត្តកណ្តាល ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្មនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលមានអាសយដ្ឋានលេខ ៧៧៨ មហាវិថីព្រះមុន្នីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី...១៨...ខែ...កញ្ញា...ឆ្នាំ២០១៨ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ...[illegible]...)។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹមថ្ងៃទី...២៩...ខែ...តុលា...ឆ្នាំ២០១៨ វេលាម៉ោង ...០៨ ម៉ោង ០០ នាទី...។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង...០៨ ម៉ោង ០០ នាទី... ថ្ងៃទី...២៩...ខែ...តុលា...ឆ្នាំ២០១៨ ។

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ធ្វើនៅ...ភ្នំពេញ... ថ្ងៃទី...១៨... ខែ...កញ្ញា... ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
**និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម**

**វង សូត** ឯកសារដេញថ្លៃ

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពអំពើពុករលួយ
- ឯកសារ កាលប្បវត្តិ